# សិទ្ធិរបស់កុមារក្នុងការទទួលបានបរិស្ថានល្អក្នុងតំបន់អាស៊ាន

## គោលការណ៍ និងការណែនាំគោលនយោបាយ








### តើកុមារមានសិទ្ធិអ្វីខ្លះ ?

សិទ្ធិកុមារ សំដៅលើអ្វីដែលកុមារគ្រប់គ្នាគួរមាន ឬអាចធ្វើបាន ដើម្បីមានជីវិតដែលល្អប្រសើរ។ សិទ្ធិទាំងនេះរួមមាន សិទ្ធិទទួលបានសុវត្ថិភាព និងសិទ្ធិ មានកន្លែងសុវត្ថិភាពសម្រាប់រស់នៅ សិទ្ធិទទួលបានការអប់រំ និងសិទ្ធិបញ្ចេញមតិអំពីការសម្រេចចិត្តដែលប៉ះពាល់ដល់ពួកគេ។នៅក្នុងកិច្ចព្រមព្រៀងដ៏សំខាន់មួយរដ្ឋាភិបាលនានាសន្យាថានឹងធានាឱ្យមានការការពារសិទ្ធិទាំងនេះសម្រាប់កុមារ។

### អ្វីទៅដែលជាបរិស្ថានល្អប្រសើរសម្រាប់សុខភាព ?



អាកាសធាតុដែលមានសុវត្ថិភាព
សម្រាប់មនុស្សគ្រប់គ្នា និង
សម្រាប់សភាវៈមាន
ជីវិតគ្រប់ប្រភេទ

អាហារមានអនាម័យ
សម្រាប់បរិភោគ និងកន្លែង
ដែលពុំទទួលរងការបំពុលសម្រាប់
រស់នៅ រៀនសូត្រ និងលេងកម្សាន្ត



ខ្យល់ស្អាតសម្រាប់ដកដង្ហើម
និងទឹកស្អាតសម្រាប់ផឹក





សកម្មភាពប្រកបដោយចីរភាព
ដើម្បីទាញប្រយោជន៍ឱ្យបានច្រើនបំផុត
ពីធនធាននាពេលបច្ចុប្បន្ន ដោយមិន
ធ្វើឱ្យមនុស្សជំនាន់ក្រោយរងទុក្ខ







## កុមារនៅទូទាំងពិភពលោកកំពុងប្រាប់មនុស្សពេញវ័យ និង រដ្ឋាភិបាលថា ពួកគេចង់រស់នៅ និងចម្រើនវ័យក្នុងបរិស្ថានល្អ។

ដើម្បីជួយឱ្យគ្រប់គ្នានៅក្នុងតំបន់អាស៊ាន ផ្តល់ការការពារ និងគោរពសិទ្ធិកុមារ ក្នុងការទទួលបានបរិស្ថានល្អ ទីភ្នាក់ងារអង្គការសហប្រជាជាតិចំនួន ៣ បានធ្វើការរួមគ្នាជាមួយនឹងអ្នកជំនាញដែលជាកុមារ និងមនុស្សពេញវ័យ ដើម្បីរៀបចំគោលការណ៍ និងការណែនាំគោលនយោបាយនេះឡើង។

UN environment programme

unicef for every child

UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER
South-East Asia Regional Office



# តើអ្វីទៅដែលហៅថា គោលការណ៍ និង ការណែនាំនយោបាយ ?

**គោលការណ៍** សំដៅលើវិធានជាមូលដ្ឋានដែលមនុស្សគ្រប់រូបចាំបាច់ត្រូវអនុវត្តតាម ដើម្បីធានាឱ្យកុមារអាចទទួលបានសិទ្ធិរបស់ពួកគេក្នុងការទទួលបានបរិស្ថានល្អសម្រាប់សុខភាព។ សរុបមានគោលការណ៍ចំនួន ៣៧។

**ការណែនាំគោលនយោបាយ** ដាក់ចេញទិសដៅដល់រដ្ឋាភិបាល សហគ្រាស សហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ និងកុមារអំពីរបៀបអនុវត្តតាមគោលការណ៍ខាងលើ។




## តើអ្នកដឹងទេ ?

អង្គការសហប្រជាជាតិបានលើកឡើងថា មនុស្សគឺជាកុមារចាប់គិតពីពេលដែលពួកគេកើតរហូតដល់មានអាយុ ១៨ឆ្នាំដែលពេលនោះពួកគេក្លាយជាមនុស្សពេញវ័យ។



# គោលការណ៍

តើមនុស្សគ្រប់គ្នានៅក្នុងតំបន់អាស៊ានគួរចងចាំអ្វីខ្លះ នៅពេលពួកគេធ្វើការសម្រេចចិត្ត និងអនុវត្តសកម្មភាព ដែលពាក់ពន្ធ័នឹងកុមារ និងបរិស្ថាន ?




## បរិស្ថានល្អ

កុមារគ្រប់រូបមានសិទ្ធិរស់នៅ និងចម្រើនវ័យក្នុងបរិស្ថានល្អប្រសើរ។




## ការចូលរួមរបស់កុមារ

កុមារគ្រប់រូបមានសិទ្ធិលើកឡើងពីគំនិតរបស់ពួកគេនិងចូលរួមក្នុងសេចក្តីសម្រេចនានា ដែលប៉ះពាល់ដល់កុមារ និងសិទ្ធិរបស់ពួកគេក្នុងការទទួលបានបរិស្ថានល្អប្រសើរ។




## ព័ត៌មានកុមារមេត្រី

កុមារគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានអំពីរបៀបរស់នៅក្នុងបរិស្ថានល្អប្រសើរ ជាភាសាដែលពួកគេយល់និងតាមរបៀបដែលជាទីចាប់អារម្មណ៍សម្រាប់ពួកគេ។




## ការអប់រំអំពីបរិស្ថាន

កុមារគ្រប់រូបមានសិទ្ធិរៀនសូត្រពីបរិស្ថាន និងរបៀបការពារបរិស្ថាន។




## ការលេងកម្សាន្ត

កុមារគ្រប់រូបមានសិទ្ធិលេងកម្សាន្តប្រកបដោយសុវត្ថិភាពនៅខាងក្រៅ ក្នុងបរិស្ថានល្អប្រសើរ។




## កិច្ចការពារពីការប្រែប្រួលអាកាសធាតុ និងការខូចខាតចំពោះបរិស្ថានធម្មជាតិ

កុមារគ្រប់រូបមានសិទ្ធិទទួលបានកិច្ចការពារពីគ្រោះថ្នាក់គ្រប់បែបយ៉ាងដែលបង្កឡើងដោយសារការប្រែប្រួលអាកាសធាតុ ការបំពុល និងការបាត់បង់រុក្ខជាតិ សត្វ ព្រមទាំងធនធានធម្មជាតិដទៃទៀត។




## បញ្ឈប់សកម្មភាពអាជីវកម្មដែលបង្កគ្រោះថ្នាក់

កុមារគ្រប់រូបមានសិទ្ធិទទួលបានកិច្ចការពារពីគ្រោះថ្នាក់គ្រប់បែបយ៉ាងដែលបង្កឡើងដោយសកម្មភាពអាជីវកម្មនានា។




## រៀបចំឱ្យកុមារអាចទទួលបានជំនួយ

កុមារគ្រប់រូបមានសិទ្ធិសុំ និងទទួលបានការគាំទ្រ និងទទួលបានយុត្តិធម៌បែបកុមារមេត្រី នៅពេលដែលពួកគេប្រឈមនឹងគ្រោះថ្នាក់ ដែលបង្កឡើងដោយសារការបំពានសិទ្ធិរបស់ពួកគេក្នុងការទទួលបានបរិស្ថានល្អប្រសើរ។




## កិច្ចការពារពីអំពើហិង្សា

កុមារគ្រប់រូបមានសិទ្ធិទទួលបានកិច្ចការពារពីការគំរាមកំហែង ឬបញ្ហាគ្រប់បែបយ៉ាង មិនថាប្រព្រឹត្តដោយនរណានោះឡើយ  នៅពេលដែលពួកគេទាមទារឱ្យមានការគោរពសិទ្ធិរបស់ពួកគេក្នុងការទទួលបានបរិស្ថានល្អប្រសើរ និងនៅពេលដែលពួកគេស្វែងរកយុត្តិធម៌ ប្រសិនបើសិទ្ធិរបស់ពួកគេពុំត្រូវបានគោរព។

មានគោលការណ៍ជាក់លាក់ចំនួន២៨ ផ្សេងទៀតស្តីអំពីកិច្ចការពារសិទ្ធិរបស់កុមារ ក្នុងការទទួលបានបរិស្ថានល្អប្រសើរ។

**សូមចងចាំ!** នេះគឺជាអ្វីសម្រាប់កុមារទាំងអស់គ្នា។ មិនប្រកាន់ថាតើអ្នកជានរណា នៅទីណានោះឡើយ។ កុមារគ្រប់រូបសុទ្ធតែមានសិទ្ធិទាំងនេះ រួមទាំងអ្នកផងដែរ។

# ការណែនាំគោលនយោបាយ

តើយើងគ្រប់គ្នាអាចរួមចំណែកអ្វីខ្លះដើម្បីធានាឱ្យមានបរិស្ថានល្អប្រសើរសម្រាប់កុមារ ?

## រដ្ឋាភិបាលអាច...



- រៀបចំច្បាប់ និងវិធានដែលទាមទារឱ្យមានការគោរពគោលការណ៍ទាំងនេះ រាប់បញ្ចូលទាំងវិធានសម្រាប់ធុរកិច្ចផងដែរ
- ធានាឱ្យកុមារបានចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តតាមរយៈការផ្ដល់ជាព័ត៌មានដែលពួកគេអាចយល់បាន
- ធានាថាសាលារៀនផ្ដល់ការអប់រំស្ដីអំពីបរិស្ថាន
- ធានាឱ្យមានការផ្ដល់ថវិកាឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យកុមារអាចធ្វើសកម្មភាពគ្រប់បែបយ៉ាងក្នុងកិច្ចការពារសិទ្ធិរបស់ពួកគេ ដោយទទួលបានបរិស្ថានល្អប្រសើរ

## ធុរកិច្ចនានាអាច...



- ពិនិត្យ និងតាមដានជាប្រចាំ ដើម្បីស្វែងយល់អំពីសកម្មភាពអាជីវកម្មនានាដែលអាចបង្កផលប៉ះពាល់ដល់កុមារ និងបរិស្ថាន ព្រមទាំងចៀសវាងសកម្មភាពទាំងឡាយណាដែលអាចបង្កឱ្យមានគ្រោះថ្នាក់កើតឡើង
- ធានាថាគ្រប់គ្នានៅក្នុងក្រុមហ៊ុនយល់ និងគោរពសិទ្ធិកុមារ ក្នុងការទទួលបានបរិស្ថានល្អប្រសើរ
- ស្ដាប់សំឡេងកុមារ មុនពេលធ្វើការសម្រេចចិត្តធុរកិច្ចអ្វីមួយ

## សហគមន៍អាច...



- ជួយឱ្យកុមារការពារសិទ្ធិរបស់ពួកគេក្នុងការទទួលបានបរិស្ថានល្អប្រសើរប្រកបដោយសុវត្ថិភាព
- ធ្វើការជាមួយកុមារ ដើម្បីណែនាំអំពីការអនុវត្តល្អៗសម្រាប់បរិស្ថាន នៅកន្លែងដែលពួកគេរស់នៅ ដូចជា “កាត់បន្ថយ-ប្រើឡើងវិញ-កែច្នៃឡើងវិញ" ជាដើម
- គាំទ្រដល់រដ្ឋាភិបាល សាលារៀន ធុរកិច្ច និងសហគមន៍ ឱ្យគោរពគោលការណ៍ទាំងអស់នេះ

## បណ្ដាញផ្សព្វផ្សាយអាច...




- រាយការណ៍អំពីអ្វីដែលរដ្ឋាភិបាល និងធុរកិច្ចនានាកំពុងធ្វើបានល្អ និងមិនបានល្អពាក់ព័ន្ធនឹងការគោរពសិទ្ធិរបស់កុមារ ក្នុងការទទួលបានបរិស្ថានល្អប្រសើរ ផលិតព័ត៌មានសម្រាប់កុមារអំពីបរិស្ថាន
- រាយការណ៍អំពីសកម្មភាពល្អៗ ដែលរៀបចំដោយកុមារដើម្បីការពារបរិស្ថាន និងប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ



នេះគ្រាន់តែជាបញ្ជីសង្ខេបអំពីអ្វីដែលឪពុកម្ដាយ គ្រូបង្រៀន និងមនុស្សពេញវ័យដទៃទៀតអាចធ្វើបានតែប៉ុណ្ណោះ។ នៅមានសកម្មភាពជាច្រើនទៀតដែលអាចធ្វើបាន ដើម្បីឱ្យកុមារអាចរស់នៅ និងចម្រើនវ័យក្នុងបរិស្ថានល្អប្រសើរសម្រាប់ពួកគេ។





# តើកុមារអាចធ្វើអ្វីខ្លះ ?

## រៀនសូត្រ



នៅសាលារៀន៖  ជម្រាបលោកគ្រូ អ្នកគ្រូ និងឪពុកម្ដាយរបស់អ្នកថា អ្នកចង់រៀនអំពីបរិស្ថាន និងសិទ្ធិកុមារ ដើម្បីទទួលបានបរិស្ថានល្អប្រសើរ។



អ្វីដែលអ្នកអាចធ្វើដោយខ្លួនឯង៖ អានសៀវភៅ ទស្សនាវីដេអូ និងចូលរួមក្នុងសកម្មភាពនានា ដែលបង្រៀនអ្នកអំពីបរិស្ថាន។

## និយាយ



ប្រាប់កុមារផ្សេងទៀត និងមនុស្សពេញវ័យ រួមទាំងឪពុកម្ដាយរបស់អ្នកផងដែរ នូវអ្វីដែលអ្នកបានរៀនអំពីបរិស្ថាន និងសិទ្ធិរបស់កុមារក្នុងការទទួលបានបរិស្ថានល្អប្រសើរ។



ប្រើប្រាស់បណ្ដាញទំនាក់ទំនងសង្គម ដើម្បីប្រាប់អ្នកដទៃទៀតអំពីអ្វីដែលអ្នកកំពុងធ្វើ ដើម្បីការពារបរិស្ថាន។



ជម្រាបលោកគ្រូ អ្នកគ្រូថា អ្នកចង់បានព័ត៌មានបែបកុមារមេត្រីស្ដីអំពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។



## លេងកម្សាន្ត



ជម្រាបឪពុកម្ដាយរបស់អ្នក និងមនុស្សពេញវ័យដទៃទៀតថាកុមារត្រូវការកន្លែងដែលមានសុវត្ថិភាពសម្រាប់លេងកម្សាន្ត។



ស្វែងរកសកម្មភាពដែលអ្នកអាចធ្វើបាន ដើម្បីការពារបរិស្ថាន ហើយក្នុងពេលជាមួយគ្នាក៏ផ្ដល់នូវភាពសប្បាយរីករាយដល់អ្នកផងដែរ។

## ចូលរួម



ជួយបង្កើតក្រុមនៅក្នុងសហគមន៍របស់អ្នក និងចូលរួមក្នុងបណ្ដាញកុមារដែលកំពុងធ្វើការ ដើម្បីការពារបរិស្ថាន និងប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។



**ចូលរួមក្នុងក្រុម និងយុទ្ធនាការនានានៅថ្នាក់តំបន់ និងអន្តរជាតិ៖**

- គំនិតផ្ដួចផ្ដើមសិទ្ធិបរិស្ថានរបស់កុមារ ( CERI )
- អង្គការយុវជនអាស៊ាន
- ក្រុមឯកទេសរបស់អង្គការសហប្រជាជាតិ ផ្នែកកុមារ និងយុវជន
- ក្រុមយុវជនប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក
- ក្រុមកុមារ និងយុវជន របស់ UNEP



# ស្វែងរកការគាំទ្រមតិ





ជម្រាបឪពុកម្តាយ លោកគ្រូ-អ្នកគ្រូរបស់អ្នក និងអ្នកដឹកនាំនៅក្នុងសហគមន៍របស់អ្នកថា កុមារគួរតែចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់សិទ្ធិ របស់ពួកគេដើម្បីទទួលបានបរិស្ថានល្អប្រសើរ។

ស្វែងរកផលប៉ះពាល់ដែលមាននៅក្នុងបរិស្ថាន នៅកន្លែងដែលអ្នករស់នៅ និងថាតើវាប៉ះពាល់ដល់មនុស្សជុំវិញអ្នកយ៉ាងដូចម្តេចខ្លះ។




នៅពេលដែលសិទ្ធិរបស់អ្នកក្នុងការទទួលបានបរិស្ថានល្អប្រសើរពុំត្រូវបានគេគោរព ចូរប្រាប់ទៅក្រុមដែលអ្នកបានចូលរួមជាមួយ ឱ្យពួកគេជួយដាក់ពាក្យបណ្តឹង។



**អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ** គឺជាកិច្ចព្រមព្រៀងដ៏សំខាន់ដែលប្រទេសនានា បានសន្យាថានឹងការពារសិទ្ធិរបស់កុមារ។ អនុសញ្ញាស្តីពីសិទ្ធិកុមារបានពន្យល់ថា តើនរណាជាកុមារ សិទ្ធិរបស់ពួកគេមានអ្វីខ្លះ និងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល។ សិទ្ធិទាំងអស់សុទ្ធតែមានលក្ខណៈប្រទាក់ក្រឡាគ្នា សិទ្ធិទាំងអស់សុទ្ធតែមានសារសំខាន់ដូចៗគ្នា ហើយគេមិនអាចដកហូតសិទ្ធិទាំងនេះចេញពីកុមារបានឡើយ។ រដ្ឋាភិបាលនៅគ្រប់ប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ាន សុទ្ធតែបានយល់ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ។

យុត្តិធម៌កុមារមេត្រី គឺជាអភិក្រមផ្តល់យុត្តិធម៌ ដែលគោរពសិទ្ធិរបស់អ្នកក្នុងនាមជាកុមារ ដោយត្រូវធ្វើការពិចារណា និងសម្របទៅតាមអាយុរបស់អ្នក តម្រូវការរបស់អ្នក ស្ថានភាពរបស់អ្នក និងកម្រិតនៃការយល់ដឹងរបស់អ្នក។ វាគឺជាយុត្តិធម៌ដែលកុមារគ្រប់រូបអាចទទួលបាន ពោលគឺយុត្តិធម៌ដែលលឿន និងផ្តល់តម្លៃដល់សំឡេងរបស់អ្នក ក្នុងដំណើរការទាំងមូល។ យុត្តិធម៌កុមារមេត្រីត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយគ្រោះថ្នាក់ដែលអ្នកអាចទទួលរងក្នុងដំណើរការនេះ ហើយយុត្តិធម៌នេះជួយការពារសិទ្ធិរបស់អ្នក។

# សេចក្តីថ្លែងអំណរគុណ

ឯកសារព័ត៌មានសង្ខេបបែបកុមារមេត្រីស្តីពី គោលការណ៍ និងការណែនាំគោលនយោបាយ ក្រោមចំណងជើងថា៖ **សិទ្ធិទទួលបានបរិស្ថានល្អប្រសើររបស់កុមារក្នុងតំបន់អាស៊ាន** ត្រូវបានផលិតឡើង ដោយមានការសហការជាមួយកុមារអាយុ ១៤-១៨ ឆ្នាំមកពីប្រទេសព្រុយណេដារ៉ូសាឡឹម កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

រចនា/ផលិតដោយ៖ QUO Bangkok

ឯកសារសង្ខេបព័ត៌មានកុមារមេត្រី ត្រូវបានរៀបចំរួចរាល់ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១។

កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP) មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) អង្គការសហប្រជាជាតិសិទ្ធិមនុស្ស (OHCHR) និងសម្ព័ន្ធសិទ្ធិកុមារអាស៊ី (CRC Asia) មិនទទួលខុសត្រូវលើផលវិបាកនានាដែលកើតចេញពីការយកឯកសារនេះទៅប្រើបន្តនោះឡើយ។

## មានសំណួរ? សូមទាក់ទង៖

**កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP)**
uneproap@un.org

**មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF)**
asiapacificinfo@unicef.org

**អង្គការសហប្រជាជាតិសិទ្ធិមនុស្ស (OHCHR)**
ohchr.bangkok@un.org

**សម្ព័ន្ធសិទ្ធិកុមារអាស៊ី (CRC Asia)**
secretariat@crcasia.org

UN environment programme 50 1972-2022 | UNITED NATIONS HUMAN RIGHTS OFFICE OF THE HIGH COMMISSIONER South-East Asia Regional Office | unicef for every child | Child Rights Coalition Asia